Khmer

medicare



# សាច់រឿងរបស់ Christine

**ក្រុមអាយុ៖** 35-40 ឆ្នាំ

**មុខរបរ៖** ការធ្វើទីផ្សារ

**ភាសាដែលនិយាយ៖** អង់គ្លេស/អារ៉ាប់

**សម្រាប់ Christine អាយុ 37 ឆ្នាំ ជនជាតិលីបង់ អូស្ត្រាលីការគ្រប់គ្រងសុខភាពគឺជាអាទិភាពប្រចាំថ្ងៃ។** ការរស់នៅដោយមានអាការៈរោគមេតាបូលីក និង ការគ្រប់គ្រងការអស់រដូវមុនកាលកំណត់ មានន័យថា សុខុមាលភាពរបស់នាងអាស្រ័យទៅលើការត្រួតពិនិត្យ ជាប្រចាំ។

ការថែទាំរបស់នាងរួមមានការទៅជួប GP ញឹកញាប់ ការបញ្ជូនបន្តទៅកាន់អ្នកឯកទេស និងការធ្វើតេស្តរោគវិនិច្ឆ័យ នានាដូចជា MRI និង CT ជាដើម។ នាងតែងតែទៅជួប GP របស់នាងរៀងរាល់បីខែម្តង។

Christine ពន្យល់ថា “នាពេលកន្លងមក ថ្លៃចំណាយផ្ទាល់ ចេញពីហោប៉ៅ នាំឱ្យមានការលំបាកផ្នែកហិរញ្ញវត្ថុក្នុង ការទៅជួប GP រៀងរាល់ពេល។ វាជាការលំបាកក្នុងរក្សា តុល្យភាពលើការចំណាយទាំងនេះ ខណៈពេលព្យាយាម គ្រប់គ្រងសុខភាពរបស់ខ្ញុំ។”

ដោយការយកចេញថ្លៃចំណាយផ្ទាល់ចេញពីហោប៉ៅសម្រាប់ ការទៅជួប GP នាងអាចចូលរួមការណាត់ជួបនានាតាម ការណែនាំ ការគាំទ្រការត្រួតពិនិត្យជាប្រចាំ និងការបន្ត ការថែទាំរបស់នាង។



*“ការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋបានផ្តល់ឱ្យខ្ញុំនូវភាព ស្ងប់ចិត្ត ក្នុងការផ្តល់អាទិភាពដល់សុខភាពរបស់ខ្ញុំ ដោយមិនខ្វល់ព្រួយអំពីការចំណាយ។ វាបញ្ជាក់ថា ការថែទាំសុខភាពប្រកបដោយគុណភាពគឺអាចចូល ប្រើបាន ហើយមានតម្លៃសមរម្យសម្រាប់សហគមន៍ របស់យើង។ ខ្ញុំសូមណែនាំមនុស្សគ្រប់គ្នាឱ្យរក្សា សកម្ម ហើយកុំរង់ចាំរហូតដល់អ្នកមិនស្រួលខ្លួនដើម្បី ស្វែងរកជំនួយ។”*

- Christine

ស្កេនកូដ QR នេះសម្រាប់ព័ត៌មានបន្ថែម

ដើម្បីស្វែងរកវេជ្ជបណ្ឌិតដែលគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋនៅជិតអ្នក សូមចូលទៅកាន់គេហទំព័រ **health.gov.au/bulkbilling**

Australian Government
Department of Health, Disability and Ageing